ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១៧ រ៉ថ.បល.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌក្រសួងរ៉ែ និង ថាមពល សម្រាប់ឆ្នាំ២០១៧

ក្រសួងរ៉ែ និង ថាមពលសូមជូនដំណឹងដល់មន្ត្រីរាជការ និស្សិត និងសាធារណជនឱ្យបានជ្រាបថា សម្រាប់ឆ្នាំ២០១៧នេះ ក្រសួងនឹងរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ក្របខណ្ឌថ្មី (**ប្រភេទ «ក»**) ចំនួន៣៧កន្លែង ឱ្យចូលបម្រើការងារ នៅតាមអង្គភាពនានាចំណុះក្រសួងរ៉ែ និង ថាមពល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ១. មុខជំនាញជ្រើសរើស

- អគ្គិសនី
- ភូគព្ភសាស្ត្រ
- សេដ្ឋកិច្ច គណនេយ្យ ធនាគារ និង ហិរញ្ញវត្ថុ
- នីតិសាស្ត្រ
- ភាសាអង់គ្លេស

### ២. លក្ខខណ្ឌជ្រើសរើស

បេក្ខជន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

២.១ ត្រូវមានសញ្ជាតិខ្មែរ

២.២ បេក្ខជន ដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬ សញ្ញាបត្រសមមូល ត្រូវមានអាយុមិនឱ្យលើសពី ៣៥ឆ្នាំ (គិតត្រឹមថ្ងៃប្រឡង)

២.៣ បេក្ខជន ដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬ សញ្ញាបត្រសមមូលត្រូវមានអាយុមិនឱ្យលើសពី៤០ឆ្នាំ (គិតត្រឹមថ្ងៃប្រឡង)

២.៤ បេក្ខជន ដែលមានសញ្ញាបត្របណ្ឌិត ឬ សញ្ញាបត្រសមមូលត្រូវបានលើកលែងលក្ខខណ្ឌអាយុ។

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

## ៣. អង្គភាពដែលត្រូវជ្រើសរើសចូលបម្រើការងារ

*៣.១ នៅទីស្តីការក្រសួង៖* ត្រូវការជ្រើសរើសចំនួន ១៩កន្លែង តាមអង្គភាពដូចខាងក្រោម៖

| ល.រ. | អង្គភាពត្រូវការជ្រើសរើស | ចំនួន |
|---|---|---|
| **១. អគ្គនាយកដ្ឋានកិច្ចការទូទៅ** | | |
| ក | នាយកដ្ឋានរដ្ឋបាល និង ព័ត៌មានវិទ្យា | ០១ កន្លែង |
| ខ | នាយកដ្ឋានបុគ្គលិក | ០២ កន្លែង |
| គ | នាយកដ្ឋានគណនេយ្យ និង ហិរញ្ញវត្ថុ | ០១ កន្លែង |
| ឃ | នាយកដ្ឋាននីតិកម្ម | ០២ កន្លែង |
| **២. អគ្គនាយកដ្ឋានថាមពល** | | |
| ក | នាយកដ្ឋានថាមពលកកើតឡើងវិញ និង ថាមពលថ្មី | ០១ កន្លែង |
| **៣. អគ្គនាយកដ្ឋានធនធានរ៉ែ** | | |
| ក | នាយកដ្ឋានជំរុញ និង អភិវឌ្ឍធនធានរ៉ែ | ០២ កន្លែង |
| ខ | នាយកដ្ឋានភូគព្ភសាស្ត្រ | ០១ កន្លែង |
| គ | នាយកដ្ឋានគ្រប់គ្រងការស្វែងរុករករ៉ែ | ០២ កន្លែង |
| **៤. អគ្គនាយកដ្ឋានប្រេងកាត** | | |
| ក | នាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត | ០២ កន្លែង |
| ខ | នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខថាមពល | ០២ កន្លែង |
| គ | នាយកដ្ឋានគ្រប់គ្រងគម្រោងសម្បទានប្រេងកាត | ០២ កន្លែង |
| ឃ | នាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ | ០១ កន្លែង |

*៣.២ នៅមន្ទីររ៉ែ និង ថាមពលខេត្ត៖* ត្រូវការជ្រើសរើសចំនួន ១៨កន្លែង តាមអង្គភាពដូចខាងក្រោម៖

| ល.រ. | អង្គភាពត្រូវការជ្រើសរើស | ចំនួន |
|---|---|---|
| ១ | មន្ទីររ៉ែ និង ថាមពលខេត្តកណ្តាល | ០១ កន្លែង |
| ២ | មន្ទីររ៉ែ និង ថាមពលខេត្តកំពង់ចាម | ០១ កន្លែង |
| ៣ | មន្ទីររ៉ែ និង ថាមពលខេត្តកំពង់ឆ្នាំង | ០១ កន្លែង |
| ៤ | មន្ទីររ៉ែ និង ថាមពលខេត្តកំពង់ធំ | ០១ កន្លែង |
| ៥ | មន្ទីររ៉ែ និង ថាមពលខេត្តពោធិ៍សាត់ | ០១ កន្លែង |
| ៦ | មន្ទីររ៉ែ និង ថាមពលខេត្តបាត់ដំបង | ០២ កន្លែង |
| ៧ | មន្ទីររ៉ែ និង ថាមពលខេត្តសៀមរាប | ០១ កន្លែង |
| ៨ | មន្ទីររ៉ែ និង ថាមពលខេត្តក្រចេះ | ០១ កន្លែង |
| ៩ | មន្ទីររ៉ែ និង ថាមពលខេត្តស្ទឹងត្រែង | ០១ កន្លែង |
| ១០ | មន្ទីររ៉ែ និង ថាមពលខេត្តបន្ទាយមានជ័យ | ០២ កន្លែង |
| ១១ | មន្ទីររ៉ែ និង ថាមពលខេត្តឧត្តរមានជ័យ | ០២ កន្លែង |

| | | |
|---|---|---|
| ១២ | មន្ទីររ៉ែ និង ថាមពលខេត្តកែប | ០១ កន្លែង |
| ១៣ | មន្ទីររ៉ែ និង ថាមពលខេត្តប៉ៃលិន | ០២ កន្លែង |
| ១៤ | មន្ទីររ៉ែ និង ថាមពលខេត្តត្បូងឃ្មុំ | ០១ កន្លែង |

## ៤. វិញ្ញាសាប្រឡង

វិញ្ញាសាប្រឡងមានពីរប្រភេទ គឺវិញ្ញាសាសរសេរ និង វិញ្ញាសាផ្ទាល់មាត់៖

*៤.១ វិញ្ញាសាសរសេររួមមាន៖*

- វិញ្ញាសាវប្បធម៌ទូទៅ ( រយៈពេល ១:៣០ នាទី ) មេគុណនឹង១
- វិញ្ញាសាភាសាអង់គ្លេសទូទៅ ( រយៈពេល ១:៣០ នាទី) មេគុណនឹង១
- វិញ្ញាសាជំនាញបច្ចេកទេស ( រយៈពេល ៣:០០ នាទី) មេគុណនឹង២

*៤.២ វិញ្ញាសាផ្ទាល់មាត់៖* សម្រាប់បេក្ខជនដែលប្រលងជាប់វិញ្ញាសាសរសេរ។

## ៥. កាលបរិច្ឆេទប្រឡង

សម្រាប់វិញ្ញាសាសរសេរ និង វិញ្ញាសាផ្ទាល់មាត់នឹងមានជូនដំណឹងនៅពេលក្រោយ។

## ៦. មណ្ឌលប្រឡង

- សម្រាប់វិញ្ញាសាសរសេរ នឹងមានជូនដំណឹងនៅពេលក្រោយ
- សម្រាប់វិញ្ញាសាផ្ទាល់មាត់ នឹងប្រព្រឹត្តទៅនៅទីស្តីការក្រសួងរ៉ែ និង ថាមពល។

## ៧. ទីកន្លែង និង កាលបរិច្ឆេទលក់ពាក្យ ទទួលពាក្យ និងឈប់ទទួលពាក្យប្រឡង

*៧.១ ទីកន្លែង និង កាលបរិច្ឆេទលក់ពាក្យ និងទទួលពាក្យ៖* ការលក់ និង ទទួលពាក្យប្រឡងប្រព្រឹត្តទៅចាប់ពីថ្ងៃជូនដំណឹងនេះតទៅ នៅរៀងរាល់ថ្ងៃធ្វើការ ពេលព្រឹកពីម៉ោង៧:៣០នាទី ដល់ម៉ោង១១:៣០នាទី និង ពេលរសៀល ពីម៉ោង១៤:៣០នាទី ដល់ម៉ោង១៧:០០ល្ងាច នៅនាយកដ្ឋានបុគ្គលិក (ជាន់ទី២) ក្រសួងរ៉ែ និង ថាមពល អគារលេខ ៧៩,៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

***លេខទូរស័ព្ទទំនាក់ទំនង៖ ០១២ ៣២១ ០០០/០១២ ៥៥ ៣៧ ០១។***

*៧.២ កាលបរិច្ឆេទឈប់លក់ពាក្យ និង ទទួលពាក្យ៖* ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ត្រឹមម៉ោង១៧:០០ល្ងាច។

## ៨. សំណុំលិខិតដែលបេក្ខជនត្រូវបំពេញ ក្នុងការដាក់ពាក្យប្រឡង

| | |
|---|---|
| ១. ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ច្បាប់ |
| ២. សេចក្តីចម្លងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និង សញ្ញាបត្រជំនាញ(បញ្ជាក់ផ្លូវការ) | ចំនួន ០១ច្បាប់ |
| ៣. ជីវប្រវត្តិសង្ខេប មានបិទរូបថត ( ៤ X ៦ ) | ចំនួន ០១ច្បាប់ |
| ៤. សលាកបត្រឯកត្តជន | ចំនួន ០២ច្បាប់ |
| ៥. រូបថតថ្មី ( ៤ X ៦ ) | ចំនួន ០២សន្លឹក |
| ៦. បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង | ចំនួន ០២ច្បាប់ |
| ៧. កិច្ចសន្យាការងារ | ចំនួន ០១ច្បាប់ |
| ៨. សេចក្តីចម្លងសំបុត្រកំណើត ឬ អត្តសញ្ញាណបណ្ណថតចម្លងមានបញ្ជាក់ផ្លូវការ | ចំនួន ០១ច្បាប់ |

៩. លិខិតថ្កោលទោស និង លិខិតបញ្ជាក់សុខភាព(ក្រោយប្រកាសលទ្ធផលជាប់ជាស្ថាពរ)ចំនួន ០១ច្បាប់

*សេចក្តីបញ្ជាក់៖*

- បេក្ខជនជាជនពិការ និង ស្ត្រី ដែលមានសមត្ថភាពសមស្រប នឹងត្រូវបានផ្តល់អាទិភាព។
- បេក្ខជន ត្រូវសរសេរបំពេញបែបបទសុំប្រឡង ចុះហត្ថលេខា និងមកដាក់ពាក្យដោយខ្លួនឯងផ្ទាល់។
- បេក្ខជនជាជនពិការ ត្រូវមានលិខិតបញ្ជាក់ពិការភាព។
- បេក្ខជន ត្រូវធ្វើលិខិតថ្កោលទោស និង លិខិតបញ្ជាក់សុខភាពជាបន្ទាន់ ក្រោយពីបានប្រឡងជាប់ជាស្ថាពរ។
- ព័ត៌មានលម្អិត សូមមកធ្វើទំនាក់ទំនងនៅនាយកដ្ឋានបុគ្គលិករៀងរាល់ម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមមន្ត្រីរាជការ និស្សិត និងសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន។

**រដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល:**

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-រដ្ឋបាលខេត្ត ដែលពាក់ព័ន្ធ
-គ្រប់អង្គភាពចំណុះទីស្តីការក្រសួងរ៉ែ និង ថាមពល
-គ្រប់មន្ទីររ៉ែ និង ថាមពលរាជធានី ខេត្ត
-ឯកសារ កាលប្បវត្តិ